# Vacancy Announcement

FTB
ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា
Foreign Trade Bank of Cambodia

# ដំណឹងជ្រើសរើសបុគ្គលិក

ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា (FTB) គឺជាធនាគារពាណិជ្ជក្នុងស្រុកទី១ នៅកម្ពុជាដែលទទួលបានការទុកចិត្តចាប់តាំងពីឆ្នាំ១៩៧៩ ។ ធនាគារ FTB បានផ្តល់ជូនអតិថិជននូវសេវាហិរញ្ញវត្ថុប្រកបដោយភាពជឿទុកចិត្ត និងសុវត្ថិភាពខ្ពស់ក្នុងធុរកិច្ចរបស់ខ្លួន ។ ផ្អែកលើចក្ខុវិស័យ ជាធនាគារពាណិជ្ជដែលមានការពេញចិត្តជាងគេក្នុងព្រះរាជាណាចក្រកម្ពុជា ធនាគារ FTB ប្តេជ្ញាបន្តគាំទ្រធុរកិច្ចរបស់អតិថិជនឲ្យកាន់តែរីកចម្រើនលូតលាស់ និងផ្តល់ជូនគ្រប់បុគ្គលិកនូវឱកាសអាជីពការងារ ដែលមានស្ថិរភាពយូរអង្វែងផងដែរ ។ ធនាគារកំពុងបន្តពង្រីកនូវវិសាលភាពប្រតិបត្តិការរបស់ខ្លួន និងពង្រឹងសមត្ថភាពបុគ្គលិកដើម្បីជួយទ្រទ្រង់នូវការរីកចម្រើនប្រកបដោយចីរភាពយូរអង្វែង។ ទន្ទឹមនឹងការពង្រីកប្រតិបត្តិការនេះធនាគារយើងខ្ញុំ កំពុងស្វែងរកនូវបេក្ខភាពដែលមានគុណវុឌ្ឍិ និងឆន្ទៈខ្ពស់ ដើម្បីចូលរួមជាមួយធនាគារ FTB "**និយោជកដ៏ប្រសើរនិងឈានមុខ**" សម្រាប់មុខងារខាងក្រោម៖

## អ្នកសំអាត (ចំនួន ០២ នាក់ បម្រើការនៅការិយាល័យកណ្តាល)

បម្រើការងារនៅការិយាល័យកណ្តាល និងត្រូវទទួលខុសត្រូវអនុវត្តការងារសំអាត ប្រកបដោយអនាម័យខ្ពស់ មានជាសុខភាព និងធានាអនុវត្តបានត្រឹមត្រូវតាមគោលការណ៍ និងនីតិវិធីក្នុងតួនាទីការងារ ។

## កិច្ចការចម្បងៗ និងការទទួលខុសត្រូវ

- សំអាតបរិវេណក្នុង-ក្រៅការិយាល័យ បន្ទប់ទឹក ចង្ក្រានបាយ ចំណតយានយន្ត និងឧបករណ៍-សម្ភារឱ្យមានរបៀបរៀបរយ អនាម័យ និងសោភ័ណភាពជានិច្ច ។
- រៀបចំឱ្យមានគ្រប់គ្រាន់ ព្រមទាំងត្រួតពិនិត្យជាប្រចាំនូវកន្ត្រក់ ឬធុងសំរាមតាមតុធ្វើការ និងរៀបចំឱ្យមានគ្រប់គ្រាន់នូវសម្ភារប្រើប្រាស់ក្នុងបន្ទប់ទឹក / បង្គន់ ធានាមិនឱ្យមានក្លិនអាក្រក់កើតឡើង ។
- រៀបចំផ្តល់ភេសជ្ជៈ (ទឹកក្តៅ-ត្រជាក់) សម្រាប់ភ្ញៀវ និងនិយោជិតឱ្យបានគ្រប់គ្រាន់ និងមានអនាម័យ ។
- បោកគក់សំអាតវាំងនន កម្រាលតុ កន្សែងជូតដៃ និងរបស់របរផ្សេងៗទៀតឱ្យបានស្អាតជាប្រចាំ ។
- ចូលរួមសន្សំសំចៃលើការប្រើប្រាស់ថាមពលអគ្គិសនី និងទឹក នៅក្នុងបរិវេណ អគារការិយាល័យ និងបន្ទប់ទឹកទាំងអស់ របស់ធនាគារ ។
- រាយការណ៍ជូនអ្នកគ្រប់គ្រង អំពីការមិនចូលរួមថែរក្សាអនាម័យរបស់បុគ្គលិកក្នុងបរិវេណការិយាល័យធនាគារ ។
- ធ្វើការងារផ្សេងទៀត តាមការចាត់តាំងរបស់អ្នកគ្រប់គ្រង។

## លក្ខណសម្បត្តិ និងបទពិសោធន៍

- យ៉ាងតិចមានសញ្ញាបត្របឋមភូមិ (សញ្ញាបត្រថ្នាក់ទី ៩ -ជាប់ឌីប្លូម ) ។
- ជានីតិជន ដែលមានសញ្ជាតិជាខ្មែរ និងចេះអាន សរសេរ ភាសាខ្មែរបានល្អ ។ ចេះភាសាអង់គ្លេស ត្រូវបានលើកទឹកចិត្ត ។
- មានភាពស្មោះត្រង់ សុចរិតភាព អត់ធ្មត់ និងសកម្មលើការងារ ។ មានបទពិសោធន៍ពាក់ព័ន្ធនឹងអនាម័យ ត្រូវបានផ្តល់អាទិភាព
- មានលក្ខណៈសម្បត្តិក្នុងការប្រាស្រ័យទាក់ទងល្អ រួសរាយ រាក់ទាក់ និងមានឥរិយាបថចេះបម្រើអតិថិជន ។
- អាចលះបង់នូវពេលវេលាផ្ទាល់ខ្លួន ដើម្បីទទួលនូវការបម្រើជូនធនាគារ និងអតិថិជនបានល្អ ។
- មានស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការងារ ក៏ដូចជាលក្ខខណ្ឌការងាររបស់ធនាគារ ។

## របៀបដាក់ពាក្យ

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមអញ្ជើញផ្ញើប្រវត្តិរូបសង្ខេប (មានបិទរូបថត) ជាមួយលិខិតអមជាភាសាខ្មែរ/អង់គ្លេសមកធនាគារតាមរយៈអ៊ីម៉ែល: HR@ftbbank.com ឬការិយាល័យកណ្តាល ស្ថិតនៅអគារលេខ ៣៣C-D ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ ឬតាមសាខាណាមួយ របស់ធនាគារពាណិជ្ជកម្មក្រៅប្រទេស នៃកម្ពុជា ។ មានតែបេក្ខជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងត្រូវបានជាប់ក្នុងបញ្ជីសម្រាំង និងត្រូវបានទូរស័ព្ទអញ្ជើញឱ្យមកចូលសម្ភាសន៍ ។
ព័ត៌មានបន្ថែមសូមទំនាក់ទំនងមកកាន់លេខទូរសព្ទ: ០៨១ ៦៦៦ ៥៩៧/០៨១ ៦៦៦ ៥៣៥